ទំនុកដំកើង១៣២-១៣៦

# ជំពូក ១៣២

***ផាទចនា** បទទំនាយពីព្រះគ្រីស្ទសោយរាជ្យនៅទីក្រុងយេរូសាឡិមថ្មី*

ជំពូក១៣២ ជាទំនុកច្រៀងតាមថ្នាក់មួយជំពូកទៀត បរិយាយពីសេចក្ដីសន្យាដែលព្រះជាម្ចាស់ផ្ដល់ដល់អ្នកដែលមានជំនឿលើទ្រង់។ ព្រះគ្រីស្ទយាងមកសោយរាជ្យនៅទីក្រុងយេរូសាឡិមថ្មី ជាទីក្រុងដែលព្រះអម្ចាស់យកចុះពីស្ថានសួគ៌មក។ បើតាមសំនួនវោហារ ព្រះបាទដាវីឌមិនមែនជាអ្នកដែលកត់ត្រាទុកគម្ពីរនេះទេ។ អ្នកប្រាជ្ញគម្ពីរភាគច្រើនយល់ថា ស្ដេចសាឡូម៉ូនជាអ្នកកត់ត្រាទំនុកដំកើងជំពូក១៣២។ ពេលនោះស្ដេចសាឡូម៉ូនសង់ព្រះវិហារទីក្រុងយេរូសាឡិមបានចប់សព្វគ្រប់ហើយ។ ទ្រង់បានបង្គាប់អោយគេហែរហឹបសញ្ញា របស់ព្រះយកមកតម្កល់ទុកនៅក្នុងវិហារ ដែលទ្រង់ទើបនឹងសង់រួចហើយ។ នៅក្នុងជំពូកនេះ យើងឃើញមានប្រើពាក្យហឹបជាច្រើនផង។

ថ្វីដ្បិតស្ដេចសាឡូម៉ូន ជាអ្នកកត់ត្រាជំពូក១៣២ បុត្ររបស់ព្រះបាទដាវីឌដែលសោយរាជ្យក្នុងជំពូកនេះ មិនមែនស្ដេចសាឡូម៉ូនទេ។ បុត្រដាវីឌដែលនិយាយនៅក្នុងជំពូក១៣២ គឺអង្គព្រះយេស៊ូវគ្រីស្ទវិញ។ កំពុងតែយើងសិក្សាគម្ពីរទំនុកដំកើងជំពូក១៣២ សូមគិតពីព្រះអម្ចាស់យេស៊ូវ ដែលទ្រង់សោយរាជ្យនៅទីក្រុងយេរូសាឡិមថ្មី។

ពួកសាសន៍អ៊ីស្រាអែលដែលធ្វើដំណើរមកពីគ្រប់ទិសទី បានធ្វើដំណើរមកដល់បរិវេណព្រះវិហារហើយ។ នៅទីនោះភ្នែកគេបានឃើញទីសន្តោសប្រោស ឃើញហឹបសញ្ញានៃព្រះយេហូវ៉ា។ ឯចិត្តរបស់គេមានចិត្តអបអរសាទរយ៉ាងខ្លាំងក្រៃលែង។

> **១ឱព្រះយេហូវ៉ាអើយ សូមទ្រង់នឹកចាំពីដាវីឌ ហើយពីគ្រប់ទាំង**
> **សេចក្តីទុក្ខព្រួយរបស់លោក ២ដែលលោកបានស្បថនឹងព្រះ**
> **យេហូវ៉ា ហើយបន់ដល់ព្រះដ៏ខ្លាំងពូកែនៃយ៉ាកុបថា ពិតប្រាកដជា**
> **ទូលបង្គំនឹងមិនចូលទៅក្នុងផ្ទះ ជាទីលំនៅរបស់ទូលបង្គំ ឬឡើង**
> **ទៅដេក នៅលើគ្រែឡើយ ៤ក៏មិនព្រមឱ្យភ្នែកទូលបង្គំដេកលក់ ឬ**
> **ឱ្យត្របកភ្នែកធ្មេចឡើយ ៥ដរាបដល់ទូលបង្គំរកបានទីកន្លែង**
> **សំរាប់ព្រះយេហូវ៉ា គឺជាពន្លាសំរាប់ព្រះដ៏ខ្លាំងពូកែនៃយ៉ាកុប**
> **(ទំនុកដំកើង១៣២:១-៥)។**

បទគម្ពីរ២សាំយ៉ូអែលជំពូក៧ ព្រះបាទដាវីឌមានចិត្តឆេះឆួលយ៉ាងខ្លាំង ចង់សង់ព្រះវិហារថ្វាយព្រះជាម្ចាស់។ បំណងធំណាស់របស់ព្រះបាទដាវីឌ គឺចង់តម្កើងព្រះជាម្ចាស់នៅក្នុងជីវិតរបស់ទ្រង់។ ទ្រង់មិនចង់សង់វិហារដាក់ព្រះក្នុងទីនោះទេ គឺគ្រាន់តែសង់ព្រះវិហារ ដើម្បីធ្វើជាជម្រកសម្រាប់ហឹបសញ្ញារបស់ព្រះតែប៉ុណ្ណោះ។

> **សូមក្រោកឡើង ឱព្រះយេហូវ៉ាអើយ សូមយាងចូលទៅក្នុងទីសំរាករបស់ទ្រង់ គឺទ្រង់ ព្រមទាំងហិបដ៏ជាព្រះចេស្តានៃទ្រង់ផង (ទំនុកដំកើង១៣២:៨)។**

ខខាងលើបញ្ជាក់ថា ស្តេចសាឡូម៉ូនបានហែរយកហិបសញ្ញាពីត្រសាលជំនុំមកតាំងជាអចិន្ត្រៃយ៍ក្នុងព្រះវិហារ ដែលលោកទើបនឹងសង់រួចនៅទីក្រុងយេរូសាឡិម។

> **ព្រះយេហូវ៉ាទ្រង់បានស្បថនឹងដាវីឌ ដោយសេចក្តីពិត ទ្រង់ក៏មិនព្រមប្រែចេញវិញឡើយ គឺថា អញនឹងយកម្នាក់ ជាផលដែលកើតពីខ្លួនឯង តាំងឡើងឱ្យអង្គុយលើបល្ល័ង្ករបស់ឯង (ទំនុកដំកើង១៣២:១១)។**

ខខាងលើសម្តែងពីអង្គព្រះយេស៊ូវគ្រីស្ទ។ យើងហ៊ានសន្និដ្ឋានយ៉ាងដូច្នេះ ពីព្រោះបុត្រាផ្ទាល់របស់ព្រះបាទដាវីឌ មិនបានសោយរាជ្យដោយសុចរិតយុត្តិធម៌ដូចគម្ពីរខាងលើបានសម្តែងទេ។ ផ្ទុយទៅវិញ ព្រះអម្ចាស់យេស៊ូវគ្រីស្ទស័ក្តិសមនឹងទទួលលក្ខណៈសម្បត្តិជាស្តេចគ្រងរាជ្យដ៏សុចរិតយុត្តិធម៌ ដូចសម្តែងក្នុងខខាងលើ។ បុត្រាផ្ទាល់របស់ព្រះបាទដាវីឌឡើងធ្វើស្តេច។ ស្តេចខ្លះក៏បានតាំងចិត្តដូចព្រះបាទដាវីឌ ស្តេចខ្លះទៀត បានប្រព្រឹត្តអំពើបាបគួរអោយស្អប់ខ្ពើម។ នៅក្នុងចំណោមស្តេចទាំងប៉ុន្មាន

ដែលសោយរាជ្យ មានស្តេចប្រាំអង្គគត់ដែលមានចិត្តស្វែងរកព្រះជាម្ចាស់ ដូចព្រះបាទដាវីឌ។ ស្តេចទាំងប្រាំអង្គនោះ បាននាំអោយមានការភ្ញាក់រឭកខាងព្រលឹងវិញ្ញាណ នៅក្នុងនគរអ៊ីស្រាអែលទាំងមូល។

**បើសិនជាកូនចៅរបស់ឯងរក្សាសេចក្តីសញ្ញារបស់អញ នឹងសេចក្តីបន្ទាល់ដែលអញនឹងបង្រៀនដល់គេ នោះកូនចៅគេនឹងអង្គុយលើបល្ល័ង្កឯងជាដរាបតរៀងទៅ (ទំនុកដំកើង១៣២:១២)។**

ឧខាងលើបញ្ជាក់រិតតែច្បាស់ទៅទៀតថា បុត្រាផ្ទាល់របស់ព្រះបាទដាវីឌមិនបានរក្សាទុកក្រឹត្យវិន័យរបស់ព្រះជាម្ចាស់។ ដោយហេតុនោះ សាសន៍អ៊ីស្រាអែលទាំងមូលត្រូវគេចាប់ធ្វើជាឈ្លើយ នៅក្រុងបាប៊ីឡូន។ ប៉ុន្តែ ទោះបីជំនួរវង្សរបស់ព្រះបាទដាវីឌ បានប្រព្រឹត្តបាបទាស់នឹងព្រះជាម្ចាស់យ៉ាងណាក៏ដោយ ព្រះជាម្ចាស់បំភ្លេចសេចក្តីសន្យា ដែលទ្រង់បានប្រទានមកដល់ព្រះបាទដាវីឌថា នឹងមានបុត្រមួយសោយរាជ្យនៅលើបល្ល័ង្ករាជ្យរបស់ព្រះបាទដាវីឌអស់កល្បជានិច្ចនោះទេ។ ព្រះគម្ពីរសញ្ញាថ្មីចាប់ផ្តើមដោយចែងថា "នេះបញ្ជីពង្សាវតារពីព្រះយេស៊ូវគ្រីស្ទ ជាវង្សាហ្លួងដាវីឌ នឹងជាជំនួរវង្សនៃលោកអ័ប្រាហាំដែរ" (ម៉ាថាយ១:១)។ ព្រះអម្ចាស់យេស៊ូវគ្រីស្ទពិតជាពូជពង្សរបស់ព្រះបាទដាវីឌ ដែលគម្ពីរទំនុកដំកើង១៣២បានចែង។

> ១៣ ដ្បិតព្រះយេហូវ៉ាទ្រង់បានរើសក្រុងស៊ីយ៉ូន ទ្រង់សព្វព្រះ
> ហឫទ័យចង់បាន សំរាប់ជាលំនៅរបស់ទ្រង់ ១៤ នេះជាទីសំរាក
> របស់អញនៅអស់កល្បជានិច្ច អញនឹងអាស្រ័យនៅទីនេះ ដ្បិត
> អញមានចិត្តចង់បានហើយ ១៥ អញនឹងឱ្យពរជាបរិបូរ ដល់ស្បៀង
> អាហាររបស់ក្រុងនេះ ហើយនឹងចំអែតមនុស្សក្រនៅក្រុងនេះ
> ដោយអាហារដ៏គ្រប់គ្រាន់ (ទំនុកដំកើង១៣២:១៣-១៥)។

បទទំនាយខាងលើ មិនទាន់បានសម្រេចជារូបរាងនៅក្នុងទីក្រុងយេរូសាឡិមបច្ចុប្បន្ននេះទេ។ ទីក្រុងយេរូសាឡិមបច្ចុប្បន្ន មានភាពរុងរឿងគួរមើលដែរ។ ប៉ុន្តែទីក្រុងនេះនៅមានអ្នកក្រីក្រ មានអំពើស្មោកគ្រោកនៅឡើយ។ បើប្រៀបធៀបនឹងទីក្រុងបរិយាយនៅក្នុងអត្ថបទខាងលើ ទីក្រុងយេរូសាឡិមសព្វថ្ងៃនេះ ខុសឆ្ងាយណាស់ពីទីក្រុងយេរូសាឡិមថ្មី។ សាសន៍អ៊ីស្រាអែលដែលមកថ្វាយបង្គំព្រះជាម្ចាស់នៅទីក្រុងយេរូសាឡិម បានធ្វើដំណើរមកដល់បរិវេណទីក្រុងយេរូសាឡិមហើយ។ ព្រះជាម្ចាស់សន្យានៅក្នុងព្រះបន្ទូលរបស់ព្រះអង្គថា នៅពេលរាស្ត្ររបស់ទ្រង់មកជួបជុំគ្នានៅវិហារទីក្រុងយេរូសាឡិម ព្រះអង្គយាងចុះមកទីនោះដើម្បីទទួលការថ្វាយបង្គំ ព្រមទាំងប្រទានពរដល់គេ។

# ជំពូក ១៣៣

*ឆាទចនា រាស្ត្របរិសុទ្ធជួបជុំគ្នាយ៉ាងសប្បាយនៅដំណាក់ព្រះ*

ជំពូក១៣៣ ជាទំនុកច្រៀងតាមថ្នាក់របស់ព្រះបាទដាវីឌ។ ជំពូកនេះខ្លីតែខ្លឹម។ អ្នកខ្លះអោយចំណងជើងជំពូក១៣៣ថា ជាទំនុកចម្រៀងបងប្អូនស្និទ្ធភ្នា។ មែនហើយ គម្ពីរទំនុកដំកើងជំពូក១៣៣ ជាទំនុកច្រៀងស្តីពីការជួបជុំគ្នានៃរាស្ត្ររបស់ព្រះជាម្ចាស់។ នៅពេលសាសន៍អ៊ីស្រាអែល ធ្វើដំណើរមកថ្វាយបង្គំព្រះអង្គនៅវិហារទីក្រុងយេរូ-សាឡិម គេនាំប្រពន្ធ នាំកូនចៅរបស់គេមកដែរ។ មិនតែប៉ុណ្ណោះ រាស្ត្ររបស់ព្រះជាម្ចាស់មានឱកាសអាចជួបជុំបងប្អូនប្រុសស្រី មិត្តភក្តិ សន្តានព្រេងលានទាំងអម្បាលមាណ ដែលរស់នៅទូទាំងផ្ទៃប្រទេស។ សម័យនោះ សាសន៍អ៊ីស្រាអែលតាំងទីលំនៅ នៅគ្រប់ទីកន្លែងក្នុងឧបទ្វីបអារ៉ាប់។ នៅក្នុងស្រុកភូមិ សាសន៍អ៊ីស្រាអែលទទួលការមើលងាយ និយាយបង្អុស ចោទប្រកាន់ និងជៀលត្មះជារៀងរាល់ថ្ងៃ។ នៅក្នុងរយៈពេលបីដងក្នុងមួយឆ្នាំ គេមានឱកាសមកជួបជុំគ្នានៅឯទីក្រុងយេរូសាឡិម ដើម្បីថ្វាយបង្គំព្រះជាម្ចាស់នៅឯដំណាក់ទ្រង់។

**មើល ដែលបងប្អូននៅមូលជាមួយគ្នា ដោយចិត្តព្រមព្រៀង នោះជាការល្អ ហើយសមគួរយ៉ាងណាទៅ (ទំនុកដំកើង១៣៣:១)។**

សាវ័កប៉ុលបង្គាប់ដល់ពួកអ្នកជឿអោយ "ខំប្រឹងរក្សាសេចក្ដីរួបរួមគ្នារបស់ព្រះវិញ្ញាណ ដោយសេចក្ដីមេត្រី ទុកជាចំណងផង" (អេភេសូ៤:៣)។ គ្រីស្ទបរិស័ទត្រូវមានការរួបរួមគ្នាក្នុងនាមព្រះយេស៊ូវគ្រីស្ទ។ យើងមិនត្រូវចែកបក្សថា ពួកយើង ពួកគេ ជាដាច់ខាត។ ប៉ុន្តែ នៅក្នុងការរស់នៅជាក់ស្តែង គ្រីស្ទបរិស័ទយើងចូលចិត្តចែកបក្សពួក លើសពីបទគម្ពីរបានអនុញ្ញាត។ យើងមិនមានចិត្តចង់ចុះចូលជាមួយគ្នាទាល់តែសោះ។ ម្នាក់ៗចង់តាំងខ្លួនធ្វើជាត្រីបាឡែនរស់ក្នុងកូនថ្លុក មិនចង់ធ្វើជាត្រីចង្វាក្នុងមហាសាគរទេ។ គម្ពីរទំនុកដំកើងជំពូក១៣៣ជំរុញចិត្តយើងថា "មើល ដែលបងប្អូននៅមូលគ្នាដោយចិត្តព្រមព្រៀង នោះជាការល្អ ហើយសមគួរយ៉ាងណាទៅ"។

**នោះធៀបដូចជាប្រេងដ៏វិសេសដែលចាក់លើក្បាល ក៏ហូរចុះមកដល់ពុកចង្កា គឺជាពុកចង្ការបស់អើរ៉ុន រួចស្រក់ទៅដល់ជាយអាវរបស់លោកផង (ទំនុកដំកើង១៣៣:២)។**

ពេលនេះ គេបានតែងតាំងលោកអើរ៉ុនធ្វើជាសម្ដេចសង្ឃ។ លើសពីលោកអើរ៉ុន ខខាងលើសម្ដែងពីព្រះវរបិតាតែងតាំងអង្គព្រះយេស៊ូវគ្រីស្ទ ធ្វើជាសង្ឃដ៏ខ្ពស់បំផុត។ ប្រេងដែលគេយកមកចាក់តាំងនៅលើអើរ៉ុន ធ្វើជាសម្ដេចសង្ឃមានក្លិនក្រអូបយ៉ាងឈ្ងុយឈ្ងប់។ ប្រេងក្រអូប ជានិមិត្តរូបនៃអង្គព្រះយេស៊ូវគ្រីស្ទ។ ព្រះវរបិតាបានតែងតាំងអង្គព្រះគ្រីស្ទធ្វើជាអង្គសង្គ្រោះរបស់មនុស្សលោក។ ងាររបស់ទ្រង់ជាសម្ដេច

សង្ឃដ៏ខ្ពស់បំផុតផង ជាមហាក្សត្រលើអស់ទាំងមហាក្សត្រផង។ គម្ពីរទំនុកដំកើងជំពូក ៤៥:៧ ថែងពីអង្គព្រះយេស៊ូវថា "ទ្រង់បានស្រឡាញ់សេចក្ដីសុចរិត ហើយស្អប់ការទុច្ចរិត ហេតុនោះបានជាព្រះ គឺជាព្រះនៃទ្រង់ បានចាក់ប្រេងថ្វាយទ្រង់ ជាប្រេងនៃសេចក្ដីត្រេកអរសាទរ លើសជាងពួកសំឡាញ់នៃទ្រង់"។ គម្ពីរអេសេគាល៣៩:២៩ បញ្ជាក់បន្ថែមថា "អញក៏នឹងមិនគេចមុខពីគេទៀតដែរ ដ្បិតអញបានចាក់វិញ្ញាណអញទៅលើពួកវង្សអ៊ីស្រាអែលហើយ នេះជាព្រះបន្ទូលនៃព្រះអម្ចាស់យេហូវ៉ា"។ ហោរាអេសេគាលទាយពីគ្រាអនាគត ដែលនៅក្នុងពេលនោះព្រះជាម្ចាស់ទ្រង់បានចាក់ព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះអង្គ ប្រៀបឧបមាដូចជាព្រះអង្គបានចាក់ប្រេងតាំងនៅលើលោកអើរ៉ុនដែរ។ ដំណើរនេះហោរាយ៉ូអែលបានទស្សន៍ទាយពីព្រះជាម្ចាស់ បញ្ជូនព្រះវិញ្ញាណបរិសុទ្ធព្រះអង្គមកលើសាសន៍អ៊ីស្រាអែល។ បទទំនាយនោះត្រូវសម្រេចឡើងនៅថ្ងៃបុណ្យទីហាសិប។ បច្ចុប្បន្ន ព្រះជាម្ចាស់បានជ្រមុជយើងក្នុងព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះអង្គ។ ការជ្រមុជអ្នកជឿទៅក្នុងព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះអង្គ គឺព្រះយេស៊ូវញែកពួកអ្នកជឿដាក់នៅក្នុងរូបកាយរបស់ទ្រង់។ ដោយសារយើងមានព្រះអម្ចាស់យេស៊ូវជាសិរសានៃពួកជំនុំ និងព្រះអង្គជាសង្ឃដ៏ខ្ពស់បំផុត យើងត្រូវរក្សាការរួបរួមគ្នាដែលព្រះវិញ្ញាណបរិសុទ្ធបានបង្កើតឡើង។

ជំពូក១៣៣បរិយាយពីការរួបរួមគ្នារបស់ពួកបរិសុទ្ធថា មានតម្លៃខ្ពស់ដូចមានសម្ដែងនៅក្នុងខខាងក្រោមះ

**ក៏ធៀបដូចជាទឹកសន្សើមនៅលើភ្នំហើម៉ូន ដែលធ្លាក់មកលើភ្នំនៃក្រុងស៊ីយ៉ូន ដ្បិតនៅទីនោះព្រះយេហូវ៉ាបានប្រទានព្រះពរ គឺជាជីវិតដ៏នៅអស់កល្បជានិច្ច (ទំនុកដំកើង១៣៣:៣)។**

គម្ពីរទំនុកដំកើងជំពូក១៣៣ខ្លី តែមានតម្លៃជាងដុំពេជ្រមួយគ្រាប់ដែលមានពន្លឺយ៉ាងត្រចះត្រចង់។

# ជំពូក ១៣៤

***បាវចនា** ទំនុកច្រៀងតាមថ្នាក់ចុងក្រោយបង្អស់*

ក្នុងគ្រានេះ ពួកអ្នកដែលធ្វើដំណើរមកថ្វាយបង្គំព្រះជាម្ចាស់នៅទីក្រុងយេរូសាឡិមបានចូលមកដល់បរិវេណព្រះវិហារហើយ។ គេជួបជុំគ្នាទាំងកង ទាំងក្រុម ទាំងគ្រួសារ។ គេនាំគ្នាលើកសម្លេងសរសើរតម្កើងព្រះជាម្ចាស់ព្រមៗគ្នា។ សម្លេងសរសើរតម្កើងព្រះអង្គលាន់ឮខ្ទរខ្ទារ ធ្វើអោយការថ្វាយបង្គំព្រះអង្គមានលក្ខណៈអ៊ឹកធឹកយ៉ាងក្រៃលែង។ យូរៗម្តង គេបន្លឺពាក្យអាម៉ែនចំនួនបីដង ឆ្លើយឆ្លងរវាងពួកសង្ឃ និងពួកបណ្តាជន។

**១ នែ អស់អ្នកបំរើរបស់ព្រះយេហូវ៉ា ដែលឈរនៅក្នុងដំណាក់ទ្រង់**
**នៅពេលយប់អើយ ចូរថ្វាយពរដល់ព្រះយេហូវ៉ាចុះ ២ ចូរប្រណម្យ**
**ដៃទៅឯទីបរិសុទ្ធ ហើយសូមឱ្យព្រះយេហូវ៉ាបានព្រះពរចុះ (ទំនុក**
**ដំកើង១៣៤:១-២)។**

ពួកសាសន៍អ៊ីស្រាអែលធ្វើដំណើរមកពីទីឆ្ងាយ។ គេរស់នៅក្នុងភូមិដែលអ្នកស្រុកនិយាយបង្ខូចពីគេ ចោទប្រកាន់គេទាំងកម្រោល ព្រមទាំងមានការរិះគន់ ព្រោះគេ

ថ្វាយបង្គំដល់ព្រះជាម្ចាស់។ ឥឡូវ គេមានឱកាសធ្វើដំណើរមកដល់ទីក្រុងយេរូសាឡិម ជាដំណាក់របស់ព្រះជាម្ចាស់តាំងនៅ។ អ្នកដែលចូលមកថ្វាយបង្គំព្រះអង្គនៅក្នុងទីក្រុង យេរូសាឡិម ជាអ្នកដែលមានចិត្តចង់ស្វែងរកព្រះជាម្ចាស់។ ដោយសារគេមានចិត្តដូច គ្នានោះហើយ បានជាគេលើកដៃឡើងថ្វាយពរដល់ព្រះជាម្ចាស់។

**សូមឱ្យព្រះយេហូវ៉ា ដែលទ្រង់បង្កើតផ្ទៃមេឃនឹងផែនដី ទ្រង់ប្រទានពរដល់អ្នករាល់គ្នា ពីក្រុងស៊ីយ៉ូនមកផង (ទំនុកដំកើង ១៣៤:៣)។**

សាសន៍អ៊ីស្រាអែលនាំគ្នាថ្វាយពរដល់ព្រះជាម្ចាស់។ លុះគេថ្វាយពរដល់ព្រះ ជាម្ចាស់រួចហើយ គេរង់ចាំព្រះជាម្ចាស់ប្រទានពរដល់ជីវិតគេ។ គម្ពីរទំនុកដំកើងជំពូក ១៣៤ជាបទសម្រាប់ថ្វាយបង្គំ។ ខ្ញុំសូមលើកទឹកចិត្តដល់ពួកជំនុំអោយយកជំពូកនេះ បញ្ចូលក្នុងកម្មវិធីថ្វាយបង្គំ ដោយអានអោយបានទៀងទាត់នៅក្នុងក្រុមជំនុំរបស់លោក អ្នក។ ខ្ញុំសូមធ្វើចំណាប់អារម្មណ៍បន្តិចពីការថ្វាយបង្គំព្រះជាម្ចាស់។ កន្លងមកក្រុមជំនុំ របស់ព្រះអង្គគ្រប់ទីកន្លែង គ្រប់និកាយ គ្រប់ក្រុម ធ្វើការថ្វាយបង្គំព្រះអង្គដោយ មានលំដាប់លំដោយយ៉ាងត្រឹមត្រូវ។ ខ្ញុំសូមសរសើរដល់ការរៀបចំបែបនោះ។ ប៉ុន្តែ ទោះខ្ញុំជឿថា ការរៀបចំពិតជាត្រូវធ្វើ យើងមិនត្រូវយកការរៀបចំមកចាក់ពុម្ពរហូត ដល់អ្នកចូលមកថ្វាយបង្គំ គ្មានសិទ្ធិសេរីភាពបញ្ចេញកាយវិការដោយមានសេរីភាពទេ។

ជូនកាលកម្មវិធីថ្វាយបង្គំព្រះអង្គមានក្បួនខ្នាតច្រើនពេក អ្នកថ្វាយបង្គំឈរនឹងដូចរូបចម្លាក់។ ឯចម្រៀងវិញ អ្នកដែលចេះច្រៀងគេច្រៀងមួយទំហឹងចាស់ៗ អ្នកដែលមិនចេះ ឈរមើលគេដូចគោមើលកុន។ ខ្ញុំយល់ថា ពេលថ្វាយបង្គំព្រះអង្គ អ្នកនាំមុខត្រូវរៀបចំអោយអ្នកថ្វាយបង្គំគ្រប់រូប មានសិទ្ធិបញ្ជាក់ទឹកចិត្តរបស់ខ្លួននៅចំពោះព្រះជាម្ចាស់។ យើងត្រូវអនុញ្ញាតអោយអ្នកថ្វាយបង្គំ មានឱកាសពោលពាក្យសរសើរដល់ព្រះអង្គ ថ្វាយព្រះពរព្រមទាំងអរព្រះគុណដល់ព្រះអង្គ ព្រមទាំងលន់តួអំពើបាបផ្ទាល់ខ្លួន។ យើងត្រូវការកម្មវិធីថ្វាយបង្គំព្រះអង្គ ដែលមានលក្ខណៈមិនប្រព្រឹត្តទៅដោយក្បួនច្បាប់ហួសហេតុពេក។ ក្នុងកម្មវិធីថ្វាយបង្គំព្រះអង្គ ម្នាក់ៗចំណាយពេលប្រកបជាមួយនឹងព្រះជាម្ចាស់ផ្ទាល់ខ្លួន។ ដូច្នេះ ពេលថ្វាយបង្គំព្រះអង្គកុំអោយឈរដូចរូបចម្លាក់ យើងត្រូវថ្វាយបង្គំព្រះអង្គដោយសម្ដែងកាយវិការ និងពាក្យសម្ដីអោយអស់ចំណង់ដែលមាននៅក្នុងចិត្តរបស់យើង។

# ជំពូក ១៣៥

*ឆាទចនា បទសរសើរថ្វាយព្រះអម្ចាស់*

ពេលនេះ យើងចូលមកដល់ទំនុកសរសើរដល់ព្រះអម្ចាស់។ សាសន៍អ៊ីស្រាអែលពោលពាក្យសរសើរដល់ព្រះជាម្ចាស់ ដ្បិតទ្រង់បានជួយដល់គេក្នុងគ្រាកន្លងទៅ។ គេអំពាវនាវសូមអោយមាត់គ្រប់គ្នា ពោលពាក្យសរសើរតម្កើងព្រះអង្គអោយអស់ពីចិត្ត។

> **[១] ចូរសរសើរដល់ព្រះយេហូវ៉ា ចូរសរសើរដល់ព្រះនាមព្រះ**
> **យេហូវ៉ា ឱពួកអ្នកបំរើរបស់ព្រះយេហូវ៉ាអើយ ចូរសរសើរទ្រង់**
> **ចុះ [២] ពួកអ្នករាល់គ្នាដែលឈរនៅក្នុងដំណាក់នៃព្រះយេហូវ៉ា គឺ**
> **ក្នុងទីព្រះលាននៃដំណាក់របស់ព្រះនៃយើងខ្ញុំអើយ [៣] ចូរសរសើរ**
> **ដល់ព្រះយេហូវ៉ា ដ្បិតព្រះយេហូវ៉ាទ្រង់ល្អ ចូរច្រៀងសរសើរដល់**
> **ព្រះនាមទ្រង់ ដ្បិតនោះពីរោះហើយ (ទំនុកដំកើង១៣៥:១-៣)។**

យើងមិនអាចថ្លែងពីសេចក្តីល្អរបស់ព្រះអម្ចាស់ ចំពោះយើងអោយអស់សេចក្តីទេ។ ទោះមានអណ្តាតមួយពាន់ ក៏យើងពោលពីសេចក្តីល្អរបស់ទ្រង់មិនគ្រាន់

ដែរ។ តើលោកអ្នកបានពោលប្រាប់ដល់អ្នកណាម្នាក់ថា ព្រះអម្ចាស់ជាព្រះនៃយើងទ្រង់ល្អដែរឬទេ? ទ្រង់ពិតជាល្អ។ យើងត្រូវថ្វាយពាក្យសរសើរដល់ទ្រង់។

> **៦ការអ្វីក៏ដោយ ដែលព្រះយេហូវ៉ាសព្វព្រះហឫទ័យចង់ធ្វើ នោះក៏បានធ្វើទៅ ទាំងនៅលើមេឃ នៅផែនដី នៅក្នុងសមុទ្រ ហើយនៅទីជំរៅទាំងប៉ុន្មានផង ៧ទ្រង់បណ្ដាលឱ្យចំហាយទឹកឡើងពីចុងផែនដីមក ទ្រង់ធ្វើឱ្យមានផ្លេកបន្ទោរសំរាប់ភ្លៀង ក៏បញ្ចេញខ្យល់ពីឃ្លាំងទ្រង់មកដែរ (ទំនុកដំកើង១៣៥:៦-៧)។**

ព្រះជាម្ចាស់បង្កើតធាតុអាកាស ពីព្រោះព្រះអង្គទ្រង់ជាអង្គនិម្មាបនិក។ ព្រះអង្គចាត់ចែងពិភពលោករបស់ទ្រង់ តាមតែព្រះហឫទ័យរបស់ទ្រង់ចង់សម្រេច។ របៀបដែលទ្រង់ចាត់ចែងលោកសន្និវាសរបស់ព្រះអង្គ ប្រហែលជាលោកអ្នកមិនចូលចិត្តទេ។ ប៉ុន្តែ ខ្ញុំសូមស្នើដល់លោកអ្នកតែប៉ុណ្ណោះចុះថា ដោយសារលោកសន្និវាសនេះជាកម្មសិទ្ធិរបស់ព្រះជាម្ចាស់ បើលោកអ្នកមិនសប្បាយចិត្ត សូមបែរមកអោយត្រូវជាមួយនឹងព្រះអង្គវិញចុះ។ ព្រះអង្គជាអង្គនិម្មាបនិកផង ជាអង្គដែលចង់ប្រោសលោះលោកអ្នកអោយរួចពីអំពើបាបរបស់លោកអ្នកផង។ ព្រះអង្គចង់អោយយើងជឿទុកចិត្តលើព្រះអង្គតែប៉ុណ្ណោះ។ បន្ទាប់ពីយើងជឿ យើងត្រូវរស់នៅក្នុងជំនឿលើព្រះជាម្ចាស់។

ខាងក្រោមនេះ ជាសេចក្ដីប្រៀបធៀបរវាងព្រះដ៏រស់ និងរូបព្រះ។

**១៥ អស់ទាំងព្រះរបស់សាសន៍ដទៃសុទ្ធតែជារូប ធ្វើពីប្រាក់នឹងមាស**
**ប៉ុណ្ណោះ ជារបស់ដែលដៃមនុស្សបានធ្វើមក ១៦ រូបទាំងនោះមាន**
**មាត់ តែមិនចេះនិយាយ មានភ្នែក តែមើលមិនឃើញ ១៧ មាន**
**ត្រចៀក តែស្តាប់មិនឮ ក៏គ្មានខ្យល់ដង្ហើមនៅក្នុងមាត់ផង ១៨ ពួក**
**ជាងដែលធ្វើរូបទាំងនោះក៏ដូចជារូបនោះឯង ព្រមទាំងពួកអ្នក**
**ដែលទុកចិត្តនឹងរូបនោះផង (ទំនុកដំកើង១៣៥:១៥-១៨)។**

បើលោកអ្នកថ្វាយបង្គំព្រះណា ចិត្តគំនិតរបស់លោកអ្នកមានលក្ខណៈដូចព្រះនោះ។ តើលោកអ្នកកំពុងថ្វាយបង្គំអ្វីសព្វថ្ងៃនេះ? លោកអ្នកពិតជាមានអ្វីមួយ ដើម្បីថ្វាយបង្គំជាប្រាកដ។ លោកអ្នកអាចថ្វាយបង្គំមាសថ្វាយបង្គំប្រាក់ ថ្វាយបង្គំឧត្តមគតិជាដើម។ វត្ថុទាំងនោះជារូបព្រះសម្រាប់មនុស្សស៊ីវិល័យ។ ទោះបីលោកអ្នកថ្វាយបង្គំមាស ប្រាក់ ទ្រព្យសម្បត្តិ កេរ្តិ៍ឈ្មោះ ឬឧត្តមគតិ របស់ទាំងនោះមិនមែនជាព្រះដ៏ពិតនិងព្រះដ៏រស់ទេ។ រូបទាំងនោះមាន មាត់ មានភ្នែក មានត្រចៀក តែមិនអាចទាក់ទងនឹងលោកអ្នកកើត។ ផ្ទុយទៅវិញ ព្រះជាម្ចាស់ដែលគង់នៅស្ថានសួគ៌ ទ្រង់អាចស្តាប់យើង ឮព្រះអង្គអាចមើលឃើញ ព្រះអង្គអាចនិយាយមកកាន់យើងបាន។ លោកអ្នកមានលក្ខណៈដូចរូបព្រះដែលលោកអ្នកថ្វាយបង្គំ។ ដូច្នេះ បើលោកអ្នកចង់មានលក្ខណៈដូចព្រះដ៏រស់ សូមថ្វាយបង្គំដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ ព្រមទាំងថ្វាយព្រះពរដល់នាមទ្រង់ផង។

**សូមឱ្យព្រះយេហូវ៉ាបានប្រកបដោយព្រះពរពីក្រុងស៊ីយ៉ូនមក ជាព្រះដែលទ្រង់គង់នៅក្រុងយេរូសាឡិម ចូរសរសើរដល់ព្រះយេហូវ៉ាចុះ (ទំនុកដំកើង១៣៥:២១)។**

ព្រះជាម្ចាស់ដែលទ្រង់បើកសម្ដែងក្នុងអង្គព្រះយេស៊ូវ មានភាពស័ក្តិសមនឹងទទួលការថ្វាយបង្គំ និងការសរសើរតម្កើងពីមាត់មនុស្សគ្រប់ជាតិសាសន៍។

# ជំពូក ១៣៦

***ឆាទចនា*** *ការថ្វាយពាក្យអរព្រះគុណដល់ព្រះ ព្រោះសេចក្តីសប្បុរសរបស់ទ្រង់*

គម្ពីរទំនុកដំកើងជំពូក១៣៦ជាបទសរសើរមួយទៀត។ បទសរសើរក្នុងជំពូក ១៣៦ បរិយាយពីព្រះគុណរបស់ទ្រង់នៅក្នុងមាបនកម្ម និងជាបទសរសើរដល់ព្រះអម្ចាស់យេស៊ូវជាអង្គសង្គ្រោះ។ ជំពូក១៣៦ ជាបទសរសើរ ទោះបីមានសត្រូវគ្រប់ទិសទី យើងនៅតែសរសើរដល់ព្រះជាម្ចាស់ ព្រោះសេចក្តីសប្បុរសរបស់ទ្រង់ស្ថិតស្ថេរនៅជានិច្ច។ លើសពីនោះ ជំពូក១៣៦ពោលពាក្យអរព្រះគុណដល់ព្រះជាម្ចាស់ ព្រោះព្រះអង្គរៀបចំអនាគតយ៉ាងភ្លឺថ្លា សម្រាប់រាស្រ្តរបស់ព្រះអង្គគ្រប់ៗរូប។ យើងត្រូវថ្វាយពាក្យអរព្រះគុណដល់ព្រះជាម្ចាស់នៃយើង ដ្បិតសេចក្តីសប្បុរសរបស់ទ្រង់ស្ថិតស្ថេរនៅអស់កល្បជានិច្ច។ នៅគ្រប់ខនីមួយៗនៅក្នុងជំពូក១៣៦មានពាក្យបន្ទរ។ ឯពាក្យបន្ទរនោះសម្តែងម្តងហើយម្តងទៀតចំនួន២៦លើកថា "សេចក្តីសប្បុរសរបស់ទ្រង់ស្ថិតស្ថេរនៅជាដរាប"។ ចូរយើងលើកសម្លេងព្រមៗគ្នាឡើងនិយាយថា "សេចក្តីសប្បុរសរបស់ទ្រង់ស្ថិតស្ថេរនៅជាដរាប"។

**ឱសូមអរព្រះគុណដល់ព្រះយេហូវ៉ា ដ្បិតទ្រង់ល្អ សេចក្ដីសប្បុរស របស់ទ្រង់ស្ថិតស្ថេរនៅជាដរាប (ទំនុកដំកើង១៣៦:១)**

ព្រះអម្ចាស់ជាព្រះនៃយើង មានសេចក្តីសប្បុរសជាបរិបូរ។ សេចក្តីសប្បុរសរបស់ទ្រង់មិនដែលរីងស្ងួតមួយវេលាណាឡើយ ទោះរដូវប្រាំង រដូវវស្សា ទោះរដូវរងារ ឬរដូវក្តៅ។ សេចក្តីសប្បុរសរបស់ទ្រង់ មានជានិច្ចយ៉ាងបរិបូររហូតអស់កល្បតរៀងទៅ។

**២ ឱសូមអរព្រះគុណដល់ព្រះដ៏ធំលើអស់ទាំងព្រះ ដ្បិតសេចក្ដីសប្បុរសរបស់ទ្រង់ស្ថិតស្ថេរនៅជាដរាប ៣ ឱសូមអរព្រះគុណដល់ព្រះអម្ចាស់ ដ៏ធំលើអស់ទាំងព្រះអម្ចាស់ ដ្បិតសេចក្ដីសប្បុរសរបស់ទ្រង់ស្ថិតស្ថេរនៅជាដរាប (ទំនុកដំកើង១៣៦:២-៣)។**

យើងត្រូវលើកតម្កើងសេចក្តីសប្បុរសរបស់ទ្រង់នៅក្នុងជីវិតរបស់យើង។ នៅក្នុងគម្ពីរអេភេសូរ២:៤ សាវ័កប៉ុលសម្តែងថា "ប៉ុន្តែ ព្រះដែលទ្រង់មានសេចក្តីមេត្តាករុណាដ៏លើសលប់ ដោយព្រោះសេចក្តីស្រឡាញ់ជាខ្លាំង ដែលទ្រង់មានដល់យើងរាល់គ្នា"។ តើលោកអ្នកចង់បានសេចក្តីសប្បុរសរបស់ទ្រង់ទេឬ? ខ្ញុំផ្ទាល់ត្រូវការសេចក្តីសប្បុរសរបស់ទ្រង់ខ្លាំងណាស់។ សេចក្តីសប្បុរសរបស់ទ្រង់ មិនដែលរីងស្ងួតឡើយ។

បើលោកអ្នកយល់ថា លោកអ្នកកំពុងប្រព្រឹត្តអំពើបាបណាមួយយ៉ាងវក់វី សូមបែរមកទទួលសេចក្ដីសប្បុរសពីព្រះអម្ចាស់ចុះ។ ទ្រង់មានសេចក្ដីសប្បុរស នឹងផ្ដល់សេចក្ដីអត់ទោសបាបដល់លោកអ្នក។ ព្រះអង្គដោះស្រាយអំពើបាបរបស់យើង ដោយប្រើសេចក្ដីសប្បុរសរបស់ទ្រង់មកលុបលាង។ យើងត្រូវថ្វាយពាក្យសរសើរដល់ព្រះជាម្ចាស់ ដ្បិតទ្រង់ជាអង្គដែលបង្កើតរបស់របរសព្វសារពើសម្រាប់ជីវិតយើងរស់នៅ។ ដូចជំពូក១៣៦ ជីវិតរបស់យើងត្រូវមានពោរពេញទៅដោយការអរព្រះគុណដល់ព្រះជាម្ចាស់ ដ្បិតសេចក្ដីសប្បុរសរបស់ទ្រង់ស្ថិតស្ថេរនៅជាដរាប។

> **៥គឺដល់ទ្រង់ដែលបានបង្កើតផ្ទៃមេឃ ដោយប្រាជ្ញា ដ្បិតសេចក្ដី**
> **សប្បុរសរបស់ទ្រង់ស្ថិតស្ថេរនៅជាដរាប ៦គឺដល់ទ្រង់ដែលបាន**
> **ក្រាលផែនដីនៅលើទឹក ដ្បិតសេចក្ដីសប្បុរសរបស់ទ្រង់ស្ថិតស្ថេរ**
> **នៅជាដរាប ៧គឺដល់ទ្រង់ដែលបានបង្កើតតួពន្លឺយ៉ាងធំទាំងប៉ុន្មាន**
> **ដ្បិតសេចក្ដីសប្បុរសរបស់ទ្រង់ស្ថិតស្ថេរនៅជាដរាប ៨គឺព្រះ**
> **អាទិត្យ សំរាប់បំភ្លឺនៅពេលថ្ងៃ ដ្បិតសេចក្ដីសប្បុរសរបស់ទ្រង់**
> **ស្ថិតស្ថេរនៅជាដរាប ៩នឹងព្រះចន្ទ ហើយផ្កាយទាំងប៉ុន្មាន សំរាប់**
> **បំភ្លឺនៅពេលយប់ ដ្បិតសេចក្ដីសប្បុរសរបស់ទ្រង់ស្ថិតស្ថេរនៅជា**
> **ដរាប (ទំនុកដំកើង១៣៦:៥–៩)។**

វគ្គខាងក្រោម ជាបទសរសើរដែលសាសន៍អ៊ីស្រាអែលថ្វាយដល់ព្រះជាម្ចាស់ ដោយព្រោះព្រះជាម្ចាស់បានទៅរំដោះគេ អោយរួចពីភាពជាទាសករនៅក្នុងប្រទេសអេស៊ីព្ទ។ ការផ្តល់សេរីភាពដល់សាសន៍អ៊ីស្រាអែល កើតឡើងដោយសារសេចក្តីសប្បុរសរបស់ព្រះជាម្ចាស់។ រឿងរាល់ជំហានដែលព្រះជាម្ចាស់រំដោះសាសន៍អ៊ីស្រាអែលអោយរួចពីទាសករ សាសន៍អ៊ីស្រាអែលនាំគ្នាពោលជាពាក្យសរសើរព្រមៗគ្នាថា "ដ្បិតសេចក្តីសប្បុរសរបស់ទ្រង់ស្ថិតស្ថេរនៅជាដរាប"។ មិនតែប៉ុណ្ណោះសាសន៍អ៊ីស្រាអែល នាំគ្នាថ្វាយពាក្យអរព្រះគុណដល់ព្រះជាម្ចាស់ ពីព្រោះទ្រង់បានប្រទានអោយគេមានកេរមរតកនៅលើផែនដីនេះ។

**[២១]ព្រមទាំងប្រទានស្រុកគេ ទុកជាមរដក ដ្បិតសេចក្តីសប្បុរសរបស់ទ្រង់ស្ថិតស្ថេរនៅជាដរាប [២២]គឺជាមរដកដល់អ៊ីស្រាអែលជាអ្នកបំរើទ្រង់ ដ្បិតសេចក្តីសប្បុរសរបស់ទ្រង់ស្ថិតស្ថេរនៅជាដរាប (ទំនុកដំកើង១៣៦:២១-២២)។**

ខ្លឹមសារក្នុងគម្ពីរទំនុកដំកើងជំពូក១៣៦ មានអត្ថប្រយោជន៍សម្រាប់សាសន៍អ៊ីស្រាអែល ក៏ដូចជាសម្រាប់យើងរាល់គ្នាដែលជារាស្ត្ររបស់ព្រះអង្គ រស់នៅក្នុងសម័យបច្ចុប្បន្ននេះដែរ។

**២៣ជាព្រះដែលបាននឹកចាំពីយើងខ្ញុំ ក្នុងកាលដែលនៅក្នុងសណ្ឋាន
ទាបថោកនៅឡើយ ដ្បិតសេចក្តីសប្បុរសរបស់ទ្រង់ស្ថិតស្ថេរនៅ
ជាដរាប ២៤ហើយបានប្រោសយើងខ្ញុំឱ្យរួចពីពួកខ្មាំងសត្រូវ ដ្បិត
សេចក្តីសប្បុរសរបស់ទ្រង់ស្ថិតស្ថេរនៅជាដរាប ២៥ជាព្រះដែល
ប្រទានឱ្យគ្រប់ទាំងសាច់មានអាហារ ដ្បិតសេចក្តីសប្បុរសរបស់
ទ្រង់ស្ថិតស្ថេរនៅជាដរាប ២៦ឱសូមអរព្រះគុណដល់ព្រះនៃស្ថាន
សួគ៌ចុះ ដ្បិតសេចក្តីសប្បុរសរបស់ទ្រង់ស្ថិតស្ថេរនៅជាដរាប
(ទំនុកដំកើង១៣៦:២៣-២៦)។**

លោកអ្នកបងប្អូនអើយ បន្ទាប់ពីលោកអ្នកសិក្សាជំពូក១៣៦ តើលោកអ្នកមានចិត្តរំភើបចង់ពោលពាក្យចេញពីក្នុងចិត្តមកថា "ហាលេលូយ៉ា" ដែរឬទេ? ព្រះនៃយើងមានភាពឧត្តមខ្ពង់ខ្ពស់ណាស់។ ចូរយើងឱនកាយ ឱនចិត្តនៅចំពោះទ្រង់ ថ្វាយបង្គំដល់ព្រះអង្គចុះ។ ព្រះអង្គស័ក្តិសមនឹងទទួលពាក្យសរសើរ ព្រមទាំងការថ្វាយបង្គំពីយើង។ យើងជាមនុស្សលោកដែលព្រះអង្គបង្កើតពីធូលីមក ត្រូវឱនក្រាបដល់ដី ដើម្បីថ្វាយបង្គំដល់ព្រះជាម្ចាស់។ ទ្រង់មានភាពឧត្តុង្គឧត្តមខ្ពង់ខ្ពស់ ឯសេចក្តីសប្បុរសរបស់ទ្រង់ស្ថិតស្ថេរនៅជាដរាប។ ទ្រង់លើកលោកអ្នកអោយរួចពីអំពើបាបដោយសារសេចក្តីសប្បុរសរបស់ទ្រង់។ ទ្រង់រក្សាលោកអ្នកអោយរស់នៅក្នុងសេចក្តីសង្គ្រោះដោយសារសេចក្តីសប្បុរសនៃទ្រង់។ ទ្រង់លើកលោកអ្នកទៅដាក់នៅក្នុងរាជ្យរបស់ទ្រង់នៅក្នុង

គ្រាអនាគត ដោយសារសេចក្ដីសប្បុរសរបស់ទ្រង់។ ចូររាស្ត្ររបស់ព្រះអង្គពោលពាក្យព្រមៗគ្នាឥឡូវនេះថា "ដ្បិតសេចក្ដីសប្បុរសរបស់ទ្រង់ស្ថិតស្ថេរនៅជាដរាប"។ សូមពោលថា អាម៉ែនបីដង លើកទីមួយ "អាម៉ែន!" លើកទីពីរ "អាម៉ែន!" លើកទីបីផងហោង "អាម៉ែន!"។

យើងស្លេះការសិក្សាគម្ពីរទំនុកដំកើងត្រឹមណេះសិនចុះ។ ទំរាំយើងជួបគ្នាលើកក្រោយ សូមព្រះជាម្ចាស់ប្រទានពរដ៏ធំឧត្ដម ដល់លោកអ្នកបងប្អូនគ្រប់ៗគ្នា។ "ដើរជាមួយនឹងព្រះ ពិតជាប្រទះនឹងព្រះយេស៊ូវជាមិនខាន!"